# កិច្ចការបញ្ចប់មេរៀនទី៤៨-បកស្រាយភ្លើង និងផ្លាកសញ្ញាចរាចរណ៍

**អំណាន:** ចូរអានអត្ថបទខាងក្រោម រួចឆ្លើយនឹងសំណួរ ។

ភ្លើងសញ្ញាចរាចរណ៍ គេដាក់ត្រង់ចំណុចផ្លូវកោងខ្វែងគ្នាច្រើនតាមទីប្រជុំជនពិសេសនៅរាជធានីភ្នំពេញ ។

ពេលភ្លើងសញ្ញានេះ មានភ្លើងពណ៌បៃតងមានន័យថា ត្រូវចេញដំណើរ។ ពេលភ្លើងសញ្ញានេះ មានពណ៌ក្រហមមានន័យថា ត្រូវឈប់។ ភ្លើងសញ្ញាពណ៌លឿងបញ្ជាក់ថា ជាសញ្ញាប្រុងប្រយ័ត្ន។ គេប្រើសញ្ញាទាំងនេះ ដើម្បីការពារកកស្ទះចរាចរណ៍ ឬគ្រោះថ្នាក់។ ផ្លាកសញ្ញាមានច្រើនដូចជាផ្លាកសញ្ញាបញ្ជា ផ្លាកសញ្ញាបម្រាម ផ្លាកសញ្ញាអាសន្ន និងផ្លាកសញ្ញាគ្រោះថ្នាក់ជាដើម។ ផ្លាកសញ្ញាគ្រោះថ្នាក់មានច្រើនប្រភេទដូចជា សញ្ញាក្បាលខ្មោច សញ្ញាការរដ្ឋានសំណង់ សញ្ញាគូសខ្វែង។ល។ ផ្លាកសញ្ញានីមួយៗ មានន័យៗខុសៗគ្នា ។ នៅលើផ្ទៃដី បើមានដាក់សញ្ញាក្បាលខ្មោច មានន័យថាទីនោះមានមីន ឬគ្រាប់មិនទាន់ផ្ទុះ ម្យ៉ាងទៀត បើនៅតាមផ្លូវមានដាក់សញ្ញាការដ្ឋាន បញ្ជាក់ឱ្យអ្នកដំណើរប្រុងប្រយ័ត្ន ព្រោះទីនោះមានការជួសជុលផ្លូវ ឬប្រព័ន្ធលូជាដើម។ ផ្លាកសញ្ញាទាំងនោះ ធ្វើឱ្យយើងដឹងពីចំណុចគ្រោះថ្នាក់ផ្សេងៗ ។

ដូច្នេះ ដើម្បីចៀសវាងគ្រោះថ្នាក់ផ្សេងៗ យើងត្រូវស្វែងយល់ពីផ្លាកសញ្ញាទាំងនោះឱ្យ បានច្បាស់លាស់ ដើម្បីរស់នៅប្រកបដោយសុខសុវត្ថិភាព ។

គូសសញ្ញា ✓ ក្នុងប្រអប់ ☐ ចម្លើយមួយដែលត្រឹមត្រូវ ។

១. តើភ្លើងសញ្ញាចរាចរណ៍គេច្រើនដាក់នៅកន្លែងណា ?

☐ ក. តាមផ្លូវជាតិ ☐ ខ. គ្រប់ផ្លូវទាំងអស់

☐ គ. ផ្លូវខ្វែងគ្នាតាមទីក្រុង ឬទីប្រជុំជន ☐ ឃ. កន្លែងមានការឆ្លងកាត់

២. តើភ្លើងសញ្ញាចរាចរណ៍មានប៉ុន្មានពណ៌ ?

☐ ក. មានពីរពណ៌ ☐ ខ. មានបីពណ៌

☐ គ. មានបីពណ៌ ☐ ឃ. មានបួនពណ៌

LIVEWORKSHEETS

៣. ពេលភ្លើងសញ្ញាចរាចរណ៍មានពណ៌បៃតង តើយើងត្រូវធ្វើដូចម្តេច ?

- [ ] ក. ត្រូវឈប់
- [ ] ខ. ត្រូវចេញដំណើរ
- [ ] គ. ត្រូវប្រុងប្រយ័ត្ន
- [ ] ឃ. ត្រូវបង្កើនល្បឿន

៤. ពេលភ្លើងសញ្ញាចរាចរណ៍មានពណ៌ក្រហម តើយើងត្រូវធ្វើដូចម្តេច ?

- [ ] ក. ត្រូវឈប់
- [ ] ខ. ត្រូវចេញដំណើរ
- [ ] គ. ត្រូវប្រុងប្រយ័ត្ន
- [ ] ឃ. ត្រូវបង្កើនល្បឿន

៥. ពេលភ្លើងសញ្ញាចរាចរណ៍មានពណ៌លឿង តើយើងត្រូវធ្វើដូចម្តេច ?

- [ ] ក. ត្រូវឈប់
- [ ] ខ. ត្រូវចេញដំណើរ
- [ ] គ. ត្រូវប្រុងប្រយ័ត្ន
- [ ] ឃ. ត្រូវបង្កើនល្បឿន

៦. តើគេប្រើ ភ្លើង និងផ្លាកសញ្ញាចរាចរណ៍ទាំងនេះដើម្បីអ្វី ?

- [ ] ក. ឃាត់រថយន្តផាកពិន័យ
- [ ] ខ. កុំឱ្យបើកបរលឿនពេក
- [ ] គ. ការពារការកកស្ទះចរាចរណ៍
- [ ] ឃ. ត្រួតពិនិត្យរថយន្ត

៧. ផ្លាកសញ្ញាសុវត្ថិភាពនានាមានអ្វីខ្លះ ?

- [ ] ក. បញ្ជា បម្រាម អាសន្ន គ្រោះថ្នាក់
- [ ] ខ. ក្រហម ខៀវ លឿង បៃតង
- [ ] គ. ក្បាលខ្មោច ការដ្ឋានសំណង់ គូសខ្វែង
- [ ] ឃ. ជ្រុង មូល ទ្រវែង ត្រីកោណ

៨. តើផ្លាកសញ្ញាក្បាលខ្មោចនៅលើផ្ទៃដីមានន័យដូចម្តេច ?

- [ ] ក. តំបន់កប់ខ្មោច
- [ ] ខ. មានមីន ឬគ្រាប់មិនទាន់ផ្ទុះ
- [ ] គ. វាលពិឃាត
- [ ] ឃ. ប្រយ័ត្នគ្រោះថ្នាក់

៩. តើផ្លាកសញ្ញាការដ្ឋានមានន័យដូចម្តេច ?

- [ ] ក. ជួសជុលផ្លូវ ឬប្រព័ន្ធលូ
- [ ] ខ. បោសសំអាតផ្លូវ
- [ ] គ. មានទួលខាងមុខ
- [ ] ឃ. រលំអគារ

១០. ដើម្បីចៀសវាងគ្រោះថ្នាក់ចរាចរណ៍ផ្សេងៗ តើយើងត្រូវស្វែងយល់ពីអ្វី ?

- [ ] ក. ចេះបើកបរស្ទាត់
- [ ] ខ. បើកបរយឺតៗ
- [ ] គ. យល់ពីភ្លើង និងផ្លាកសញ្ញាឱ្យបានច្បាស់
- [ ] ឃ. វាយដំ បៀតបៀន

LIVEWORKSHEETS

➢ សំណេរ

១. ចូរពន្យល់ពាក្យ " ចរាចរណ៍ ប្រយ័ត្ន " ខាងក្រោមឱ្យបានត្រឹមត្រូវ ។

➢ ប្រយ័ត្ន ( ) ..........................................................................................................

➢ សុវត្ថិភាព ( ) ...................................................................................................

➢ ចរាចរណ៍ ( )......................................................................................................

២. ចូរពន្យល់ពីភ្លើងសញ្ញាចរាចរណ៍ខាងក្រោម ។

ក.

| | | | | |
|---|---|---|---|---|
| ពណ៌ក្រហម | ត្រូវឈប់។ | ភ្លើងសញ្ញា | ថា | មានន័យ |

..........................................................................................................

ខ.

| | | | | |
|---|---|---|---|---|
| ពណ៌លឿង | ជាសញ្ញា | បញ្ជាក់ថា | ប្រុងប្រយ័ត្ន។ | ភ្លើងសញ្ញា |

..........................................................................................................

គ.

| | | | | |
|---|---|---|---|---|
| ពណ៌បៃតង | ថាត្រូវ | ភ្លើងសញ្ញា | មានន័យ | ចេញដំណើរ។ |

..........................................................................................................

៣. ចូរគូសភ្ជាប់ពាក្យខាងក្រោមឱ្យត្រូវនឹងរូបភាព ។



ក. ហាមស៊ីផ្លេ

ខ. កុមារឆ្លងកាត់ញឹកញាប់





គ. ហាមជក់បារី

ក. មានការដ្ឋាននៅខាងមុខ



LIVEWORKSHEETS